**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានឯកអគ្គរាជទូតកម្ពុជា**
**ប្រចាំអូស្ត្រាលី**

លេខ: 246/20 REC/CBR

# សេចក្តីប្រកាសព័ត៌មាន

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលី មានការហួសចិត្តនិងសោកស្តាយបំផុតចំពោះជនអគតិជួរជាតិពីរបីនាក់រស់នៅប្រទេសអូស្ត្រាលីដែលតាំងខ្លួនតំណាងឲ្យសហគមន៍ខ្មែរ មានចេតនាយង់ឃ្នងខិតខំរិះរកគ្រប់មធ្យោបាយបំផ្លិចបំផ្លាញផលប្រយោជន៍ប្រជាកសិករខ្មែរ ជាពិសេសលើវិស័យស្រូវអង្ករកម្ពុជានាំចូលមកកាន់ទីផ្សារប្រទេសអូស្ត្រាលី នៅខណៈពេលប្រជាកសិករកំពុងទទួលរងផលប៉ះពាល់ហានិភ័យពីជំងឺរាតត្បាតកូវីដ១៩ និងគ្រោះជំនន់ទឹកភ្លៀងក្នុងឆ្នាំនេះ។ ទង្វើនេះធ្វើឡើងដោយក្រុមសកម្មជនអតីតគណបក្សសង្គ្រោះជាតិនៅតំបន់មួយនៃប្រទេសអូស្ត្រាលីចេញមុខដោយឈ្មោះ ខៀវ ដារ៉ា ដែលបានតាំងខ្លួនឯងថាជាអ្នកតំណាងឱ្យសហគមន៍ខ្មែរនៅអូស្ត្រាលីក្រោមការជួយជ្រោមជ្រែងបំប៉ោងសម្លេងពីវិទ្យុអាស៊ីសេរីកាលពីថ្ងៃទី១៤ខែវិច្ឆិកានេះ ដោយបានផ្ញើលិខិតដែលរៀបចំដោយមេក្លោងឈ្មោះ Ek Sawathey រស់នៅទីក្រុងស៊ីដនី ទៅតំណាងរាស្ត្រមួយរូបឈ្មោះ Anthony Byrne នៅរដ្ឋ Victoria ដោយបានមួលបង្កាច់ថា អង្កររបស់កម្ពុជាដែលបាននិងកំពុងនាំចូលមកអូស្ត្រាលី មានជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សនៅកម្ពុជា។ ការចោទប្រកាន់នេះ គឺជាការប្រឌិតសុទ្ធសាធ មានចេនាទុច្ចរិតដើម្បីរាំងទីផ្សារនិងបំផ្លាញកេរ្តិ៍ឈ្មោះអង្ករកម្ពុជាដែលពិភពលោកទទួលស្គាល់និងមានចេតនាបំផ្លិចបំផ្លាញផ្ទាល់ទៅលើផលប្រយោជន៍ប្រជាកសិករខ្មែរ។

សូមជម្រាបថា ច្រើនឆ្នាំមកនេះរាជរដ្ឋាភិបាលកម្ពុជាតែងយកចិត្តទុកដាក់ខ្ពស់ជានិច្ចដល់ប្រជាកសិករដែលជាម្ចាស់ស្រែចំការជាង ២.៥លានហិកតា ដោយផ្តល់កិច្ចការពារនិងផ្តល់អត្ថប្រយោជន៍ផ្សេងៗ ដូចជាការផ្តល់ប័ណ្ណគ្រប់គ្រងកម្មសិទ្ធិដីធ្លីដែលមិនអាចឱ្យជនណាមួយមករំលោភបំពានឬយកជាកម្មសិទ្ធិបានឡើយ ផ្តល់ការលើកលែងពន្ធនៃការបង់ពន្ធលើដីស្រែចំការនិងពន្ធគ្រប់ប្រភេទលើធាតុចូលកសិកម្ម ផ្តល់គ្រាប់ពូជ សម្ភារៈកសិកម្មផ្សេងៗ បណ្តុះបណ្តាលជំនាញដាំដុះដើម្បីទទួលបានទិន្នផលនិងគុណភាពខ្ពស់ ខិតខំស្វែងរកនិងពង្រីកទីផ្សារជូនគាត់ជាដើម។

ក្នុងរយៈពេល១០ខែនៃឆ្នាំ២០២០នេះ កម្ពុជាបាននាំអង្ករមកប្រទេសអូស្ត្រាលីបានចំនួន២៥.៩៩៤ តោន កើនឡើង៥៣%បើធៀបរយៈពេល១០ខែដូចគ្នានៃឆ្នាំ២០១៩។ នេះជាមោទនភាពមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត ឈ្លាសវៃ និងបិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងកិច្ចសហការរបស់រដ្ឋាភិបាលអូស្ត្រាលីជួយកសិករនិងវិស័យស្រូវអង្ករកម្ពុជា។ ជាក់ស្តែងកាលថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ ក្នុងឱកាសអញ្ជើញទស្សនកិច្ចរោងម៉ាស៊ីនកិនស្រូវដ៏ធំមួយរបស់ក្រុមហ៊ុនអេមរ៉ាយស៍ (Amru Rice Cambodia Co., Ltd) នៅខេត្ត

កំពង់ធំ លោក Pablo Kang ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា បានសំដែងសេចក្តីរីករាយនិងសាទរចំពោះការនាំចេញអង្ករបស់កម្ពុជាមកកាន់ប្រទេសអូស្ត្រាលីដែលបាននិងកំពុងកើនឡើងជាបន្តបន្ទាប់។ សហគមន៍ខ្មែរទាំងអស់រស់នៅប្រទេសអូស្ត្រាលីមានការសាទរគាំទ្រពេញទំហឹង និងជម្រុញលើកទឹកចិត្តចំពោះការនាំអង្ករនិងផលិតផលកសិកម្មផ្សេងៗរបស់កម្ពុជាមកកាន់ទីផ្សារអូស្ត្រាលីដើម្បីជួយលើកស្ទួយជីវភាពប្រជាកសិករឱ្យកាន់តែធូរធារថែមទៀត និងបដិសេធទាំងស្រុងនូវរាល់ទង្វើដែលមានចេតនាបំផ្លាញកេរ្តិ៍ឈ្មោះអង្ករកម្ពុជានិងផលប្រយោជន៍ប្រជាកសិករខ្មែរ។

ករណីនេះ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលី សូមថ្កោលទោសធ្ងន់ធ្ងរចំពោះក្រុមជនបំផ្លាញផលប្រយោជន៍ប្រជាកសិករនិងប្រយោជន៍ជាតិ និងសូមអំពាវនាវដល់ប្រជាកសិករនិងប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស សូមកុំជឿការបោកប្រាស់ ការញុះញង់ និងប្រជាភិថុតរបស់ក្រុមអគតិជ្រុលនិយមទាំងនេះឲ្យសោះ ក្រុមនេះពុំបានជួយអ្វីក្រៅពីការខិតខំរិះរកមធ្យោបាយបំផ្លិចបំផ្លាញស្រុកទេសដែលកំពុងរីកចម្រើនឡើយ។

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលី សូមថ្លែងអំណរគុណដល់ប្រទេសនានា ជាពិសេសប្រទេសអូស្ត្រាលីដែលបាននិងកំពុងជួយគាំទ្រដល់វិស័យស្រូវអង្ករកម្ពុជា ការបើកទីផ្សារដល់កម្ពុជា និងសូមអរគុណដល់ក្រុមហ៊ុនទាំងអស់ដែលកំពុងនាំអង្ករនិងផលិតផលកសិកម្មផ្សេងៗរបស់កម្ពុជាមកកាន់ទីផ្សារប្រទេសអូស្ត្រាលី។

កង់បេរ៉ា ថ្ងៃទី 18 ខែវិច្ឆិកា ឆ្នាំ២០២០